# របៀបដាក់ពាក្យសុំ
# និងរបៀបប្រើ

# ជំនួយ
# អាហារ
# ជាមូលដ្ឋាន



Washington State
Department of Social
& Health Services

DSHS 22-297(CA) (Rev. 6/11)

# មាតិកា


បុព្វកថា .................................................1

ការដាក់ពាក្យសុំជំនួយអាហារជាមូលដ្ឋាន

តើនរណាអាចទទួលជំនួយអាហារជាមូលដ្ឋាន? .2

តើខ្ញុំដាក់ពាក្យសុំជំនួយអាហារជាមូលដ្ឋានរបៀបណា? .........................................2

តើនឹងមានអ្វីកើតឡើង នៅក្រោយពេលខ្ញុំដាក់ពាក្យសុំរបស់ខ្ញុំរួចហើយ? .........................3

តើខ្ញុំគួរនាំយកអ្វីខ្លះតាមខ្លួន ទៅធ្វើសម្ភាសន៍?....4

តើនឹងមានអ្វីកើតឡើង ប្រសិនបើស្ថានភាពក្នុងក្រុមគ្រួសាររបស់ខ្ញុំមានការផ្លាស់ប្តូរ? .............4

ប្រសិនបើខ្ញុំមានលក្ខណសម្បត្តិ, តើខ្ញុំនឹងទទួលបានជំនួយអាហាររបស់ខ្ញុំនៅពេលណា?..........5

តើខ្ញុំនឹងទទួលជំនួយអាហារជាមូលដ្ឋានបានរយៈពេលយូរប៉ុណ្ណា? ...................................6

តើក្រសួងមានច្បាប់ស្តីពីការមិនរើសអើងឬទេ? ..7

ការប្រើប្រាស់ជំនួយអាហារជាមូលដ្ឋាន

តើប័ណ្ណ Washington EBT QUEST ជាអ្វី? .8

តើលេខ EBT PIN ជាអ្វី?...........................9

តើអ្នកកាន់ប័ណ្ណជំនួសជាអ្វី?........................9

តើខ្ញុំគួរទូរស័ព្ទទាក់ទងទៅនាយកដ្ឋានសេវាបម្រើភ្ញៀវ EBT នៅពេលណា?.................10

តើខ្ញុំអាច និងមិនអាចធ្វើអ្វីបានខ្លះជាមួយប័ណ្ណ EBT និងជំនួយរបស់ខ្ញុំ?........................... 11

សំណួរដែលគេសួរជាញឹកញាប់ស្តីអំពីប័ណ្ណ EBT និងចម្លើយ ..................................... 13

# បុព្វកថា

សេចក្តីណែនាំនេះមានផ្ទុកពត៌មានស្តីអំពីជំនួយអាហារជាមូលដ្ឋាន (Basic Food) ព្រមទាំងចម្លើយទៅនឹងសំណួរនានាស្តីអំពីរបៀបដាក់ពាក្យសុំ និងរបៀបប្រើជំនួយអាហារជាមូលដ្ឋាន។

ជំនួយអាហារជាមូលដ្ឋានបានបង្កើតឡើង ដើម្បីជួយរួមចំណែកក្នុងកញ្ចប់ប្រាក់ សម្រាប់ទិញម្ហូបអាហាររបស់គ្រួសារ។ គ្រួសារភាគច្រើនត្រូវតែចំណាយប្រាក់ពីហោប៉ៅរបស់ខ្លួន បន្ថែមទៅលើជំនួយអាហារជាមូលដ្ឋាន ដើម្បីអាចទិញអាហារបានគ្រប់គ្រាន់សម្រាប់មួយខែ។

ជំនួយអាហារជាមូលដ្ឋានបានផ្តល់ជូន ដោយផ្អែកលើទំហំគ្រួសារ និងប្រាក់ចំណូលរបស់គ្រួសារមួយ។ ថ្លៃនៃការចំណាយខ្លះក៏ត្រូវបានចាត់ទុកជាកត្តាវិភាគសម្រាប់ការផ្តល់ជំនួយនេះដែរ ដែលរួមមានដូចជា ៖

- ថ្លៃជួលផ្ទះ និងថ្លៃឃ្មធីលីធី
- ថ្លៃជួលមនុស្សមើលកូន ខណៈពេលចេញទៅធ្វើការ ឬរកការងារធ្វើ
- ថ្លៃបង់អាហារកិច្ចចិញ្ចឹមកូន សម្រាប់បណ្តាកូនៗដែលរស់នៅក្រៅផ្ទះ
- ថ្លៃវេជ្ជសាស្ត្រ(ពេទ្យ) ដែលបានបង់ដោយមនុស្សវ័យចាស់ជរា ឬពិការ

លោកអ្នកអាចប្រើកម្មវិធីបទដ្ឋានប៉ាន់ជំនួយ (Benefit Estimator) របស់យើង ដើម្បីគិតគូរមើល ថាតើលោកអ្នកមានគុណសម្បត្តិទទួលជំនួយអាហារជាមូលដ្ឋានឬទេ ហើយបើមាន តើលោកអ្នកអាចទទួលបានប៉ុន្មានៗ។ លោកអ្នកអាចរកបទដ្ឋានប៉ាន់ជំនួយនេះនៅ www.foodhelp.wa.gov លើបដាដែលមានឈ្មោះថា "Basic Food"។



**កាលណាលោកអ្នកមានគុណសម្បត្តិទទួលជំនួយអាហារជាមូលដ្ឋាន, នោះលោកអ្នកក៏មានគុណសម្បត្តិទទួលបានជំនួយផ្សេងៗទៀតមួយចំនួនដែរ ៖**

- កូនៗរបស់លោកអ្នកនឹងបានចុះឈ្មោះក្នុងកម្មវិធីអាហារឥតគិតថ្លៃនៅតាមសាលារៀនរបស់ពួកគេជាស្វ័យប្រវត្តិ;
- លោកអ្នកអាចទិញសេវាទូរស័ព្ទក្នុងមូលដ្ឋានបានថោក; និង
- លោកអ្នកមានគុណសម្បត្តិស្របតាមតេស្តប្រាក់ចំណូលសម្រាប់កម្មវិធីស្ត្រី, ទារក, និងកុមារ (Women, Infants and Children, WIC)។

ប្រសិនបើលោកអ្នកចង់ជ្រាបពត៌មានពិស្តារបន្ថែម ឬមានសំណួរជាក់លាក់ស្តីអំពីស្ថានភាពរបស់លោកអ្នក, នោះសូមទូរស័ព្ទទាក់ទងលេខ 1-877-501-2233 ឬមួយក៏អញ្ជើញចូលទៅកាន់គេហទំព័រ www.foodhelp.wa.gov ។

## តើនរណាអាចទទួលជំនួយអាហារជាមូលដ្ឋាន?

### ដើម្បីទទួលជំនួយអាហារជាមូលដ្ឋាន, លោកអ្នកត្រូវតែ ៖

- រស់នៅក្នុងរដ្ឋវ៉ាស៊ីនតោន
- មានប្រាក់ចំណូលក្រោម 200% នៃបន្ទាត់ក្រីក្ររបស់រដ្ឋាភិបាលសហព័ន្ធ (Federal Poverty Level) ។
- មានលក្ខណៈស្របតាមលក្ខខណ្ឌតម្រូវសម្រាប់ជនជាតិអាមេរិកាំង ឬជនជាតិបរទេសដែលរស់នៅលើទឹកដីសហរដ្ឋអាមេរិក។

### លោកអ្នកត្រូវតែមិនមែនជា ៖

- ជនឧក្រិដ្ឋដែលកំពុងរត់គេចពីច្បាប់
- ជនជាតិបរទេសដែលគ្មានក្រដាសស្នាមស្របច្បាប់

អាចមានលក្ខខណ្ឌតម្រូវដទៃៗទៀត ដោយផ្អែកលើស្ថានភាពនៃគ្រួសាររបស់អ្នក។

## តើខ្ញុំដាក់ពាក្យសុំជំនួយអាហារជាមូលដ្ឋានរបៀបណា?

### មានរបៀបបីយ៉ាង ដើម្បីដាក់ពាក្យសុំជំនួយអាហារជាមូលដ្ឋាន ៖

- តាមអ៊ីនធឺណិតនៅ www.washingtonconnection.org
- តាមការចូលទៅដាក់ពាក្យសុំដោយផ្ទាល់ក្នុងការិយាល័យរបស់ក្រសួងសេវាសង្គមកិច្ចនិងសុខាភិបាល (DSHS Community Service Office) ប្រចាំមូលដ្ឋានរបស់លោកអ្នក, ឬ
- តាមការផ្ញើលិខិតដាក់ពាក្យសុំតាមសំបុត្រទៅកាន់ ៖

  DSHS Customer Service Center
  PO Box 11699
  Tacoma, WA 98411-6699

លោកអ្នកអាចស្នើសុំឲ្យគេផ្ញើលិខិតដាក់ពាក្យសុំ ទៅជូនលោកអ្នកដោយទូរស័ព្ទទាក់ទងទៅលេខ 1-877-501-2233 ។

ចូរបំពេញ ហើយផ្ញើលិខិតដាក់ពាក្យសុំរបស់លោកអ្នកត្រឡប់ទៅការិយាល័យវិញ ឲ្យបានឆាប់រហ័សតាមដែលលោកអ្នកអាចធ្វើទៅបាន។ បើលោកអ្នកមានគុណសម្បត្តិ, នោះជំនួយរបស់លោកអ្នកនឹងចាប់ផ្តើមពីថ្ងៃ ដែលលោកអ្នកបានផ្ញើលិខិតដាក់ពាក្យសុំរបស់លោកអ្នកទៅវិញ។ យើងនឹងពិនិត្យមើលសេចក្តីស្នើសុំរបស់លោកអ្នក នៅក្នុងរយៈពេល 30 ថ្ងៃ ។



បើលោកអ្នកមានប្រាក់តិច ឬគ្មានសោះ ហើយត្រូវការជំនួយជាបន្ទាន់, នោះលោកអ្នកអាចនឹងមានគុណសម្បត្តិទទួលបានសេវាពន្លឿន។ នេះមានន័យថា យើងនឹងធ្វើសម្ភាសន៍លោកអ្នក ហើយបើសិនជាមានលក្ខណសម្បត្តិ, នោះយើងនឹងផ្តល់ជំនួយអាហារជូនលោកអ្នក នៅក្នុងរយៈពេលប្រាំពីរថ្ងៃ។

## តើនឹងមានអ្វីកើតឡើង នៅក្រោយពេលខ្ញុំដាក់ពាក្យសុំរបស់ខ្ញុំរួចហើយ?

នៅពេលណាយើងទទួលបានលិខិតដាក់ពាក្យសុំរបស់លោកអ្នកហើយ, នោះយើងនឹងហៅលោកអ្នកធ្វើសម្ភាសន៍ ដើម្បីធានាថា យើងយល់ពត៌មានទាំងអស់លើលិខិតដាក់ពាក្យសុំនេះ។ ការធ្វើសម្ភាសន៍អាចនឹងធ្វើឡើងតាមទូរស័ព្ទ ឬតាមការិយាល័យសេវាសហគមន៍របស់ក្រសួងសេវាសង្គមកិច្ចនិងសុខាភិបាលប្រចាំមូលដ្ឋានរបស់លោកអ្នក។ ដូច្នេះលោកអ្នកនឹងទទួលបានការហៅទូរស័ព្ទពីយើង ឬសំបុត្រដាក់ពេលណាត់ជួបធ្វើសម្ភាសន៍មួយច្បាប់ ដែលនឹងជម្រាបប្រាប់លោកអ្នកអំពីថ្ងៃ និងពេលម៉ោងសម្រាប់ការធ្វើសម្ភាសន៍របស់លោកអ្នក។

### នៅក្នុងអំឡុងពេលធ្វើសម្ភាសន៍, យើងនឹង ៖

- ពន្យល់ប្រាប់លោកអ្នកអំពីបទបញ្ញត្តិនៃកម្មវិធី;
- សួរលោកអ្នកអំពីពត៌មានលើលិខិតដាក់ពាក្យសុំរបស់លោកអ្នក;
- សុំលោកអ្នកឲ្យបង្ហាញភ័ស្តុតាងបញ្ជាក់អំពីពត៌មានមួយចំនួន;
- ប្រគល់ជូនលោកអ្នកនូវសំណៅចម្លងស្តីអំពីសិទ្ធិ និងការទទួលខុសត្រូវរបស់លោកអ្នក;
- ពន្យល់ប្រាប់លោកអ្នកអំពីគោលបំណង, ការប្រើប្រាស់ត្រឹមត្រូវ, និងទោសបញ្ញត្តិនៃការប្រើប្រាស់មិនត្រឹមត្រូវនូវកម្មវិធីជំនួយអាហារ;
- ពន្យល់ប្រាប់លោកអ្នកអំពីខ្លឹមសារផ្សេងៗ ដែលលោកអ្នកមិនយល់។

បើលោកអ្នកត្រូវការអ្នកជួយលោកអ្នកក្នុងការធ្វើសម្ភាសន៍, នោះលោកអ្នកអាចស្នើសុំជនណាម្នាក់ ដែលស្គាល់ស្ថានភាពរបស់លោកអ្នកច្បាស់លាស់ ឲ្យដាក់ពាក្យសុំ និងធ្វើសម្ភាសន៍ក្នុងនាមរបស់លោកអ្នក។ ជននេះត្រូវបានគេហៅថា អ្នកតំណាងពេញសិទ្ធិ (authorized representative)។

## តើខ្ញុំគួរនាំយកអ្វីខ្លះតាមខ្លួន ទៅធ្វើសម្ភាសន៍?

**លោកអ្នកត្រូវតែផ្តល់ភស្តុតាងបញ្ជាក់អំពី ៖**

- អត្តសញ្ញាណសម្គាល់ខ្លួនរបស់លោកអ្នក;
- ប្រាក់ចំណូលគ្រួសារ;
- ស្ថានភាពអន្តោប្រវេសន៍នៃសមាជិកគ្រួសាររបស់លោកអ្នក ដែលមិនមែនជាជនជាតិអាមេរិកាំង, ដែលក្នុងនោះរួមទាំងពត៌មានស្តីអំពីប្រាក់ចំណូល និងធនធានរបស់អ្នកធានារបស់លោកអ្នក ប្រសិនបើអនុវត្ត។

**យើងក៏អាចនឹងស្នើសុំលោកអ្នកឲ្យផ្តល់ភស្តុតាងបញ្ជាក់អំពីពត៌មានដែលមិនច្បាស់លាស់ណាមួយផងដែរ។**

នៅក្រោយពេលធ្វើសម្ភាសន៍, យើងនឹងប្រគល់ជូនលោកអ្នកនូវសំបុត្រមួយច្បាប់ ដែលមានចុះរាយនូវភស្តុតាងនានា ដែលយើងនៅត្រូវការជាបន្ថែមទៀតនៅឡើយ។ យើងនឹងជួយលោកអ្នក ដើម្បីស្វែងរកភស្តុតាងទាំងប៉ុន្មាន ដែលយើងត្រូវការ នៅក្នុងអំឡុងពេលធ្វើសម្ភាសន៍របស់លោកអ្នក។ លោកអ្នកមានពេលយ៉ាងតិចណាស់ដប់ថ្ងៃដើម្បីផ្តល់ភស្តុតាងទាំងនោះមកយើង។

## តើនឹងមានអ្វីកើតឡើង ប្រសិនបើស្ថានភាពក្នុងក្រុមគ្រួសាររបស់ខ្ញុំមានការផ្លាស់ប្តូរ?

ប្រសិនបើក្រុមគ្រួសាររបស់លោកអ្នកទទួលតែជំនួយអាហារជាមូលដ្ឋាន (Basic Food) មួយមុខ ពីក្រសួងរបស់យើង, នោះលោកអ្នកត្រូវតែប្រាប់យើង ថាតើប្រាក់ចំណូលសរុបដុលនៃក្រុមគ្រួសាររបស់លោកអ្នកមានចំនួនលើសពី 200% នៃបន្ទាត់ក្រីក្ររបស់រដ្ឋាភិបាល



សហព័ន្ធឬទេ។ លោកអ្នកអាចប្រាប់យើងអំពីការផ្លាស់ប្តូរតាមរយៈនៃការសរសេរសំបុត្រជាលាយលក្ខណ៍អក្សរ, ទូរស័ព្ទ, ឬអ៊ីនធឺណិត នៅ www.washingtonconnection.org។ លោកអ្នកត្រូវតែរាយការណ៍ប្រាប់យើងអំពីការផ្លាស់ប្តូរ ឲ្យទាន់ថ្ងៃទី 10 នៃខែមួយ បន្ទាប់ពីខែដែលប្រាក់ចំណូលគ្រួសារលោកអ្នកបានកើនឡើង។ ឧទាហរណ៍, ប្រសិនបើការផ្លាស់ប្តូររបស់លោកអ្នកបានកើតឡើងនៅថ្ងៃនេះ, នោះលោកអ្នកត្រូវតែរាយការណ៍ប្រាប់យើងនៅថ្ងៃទី 10 នៃខែបន្ទាប់នេះ។

ប្រសិនបើក្រុមគ្រួសាររបស់លោកអ្នកបានទទួលជំនួយអ្វីផ្សេងទៀតបន្ថែមលើជំនួយអាហារជាមូលដ្ឋាន, នោះលោកអ្នកត្រូវតែរាយការណ៍ប្រាប់យើង ទៅតាមលក្ខខណ្ឌតម្រូវនៃច្បាប់ Washington Administrative Code (ក្រមរដ្ឋបាលនៃរដ្ឋវ៉ាស៊ីនតោន, WAC) 388-418-0005 ។

យើងនឹងជម្រាបប្រាប់លោកអ្នកជាលាយលក្ខណ៍អក្សរ ថាតើការផ្លាស់ប្តូរនេះនឹងប៉ះពាល់ដល់ជំនួយអាហាររបស់លោកអ្នកយ៉ាងណាខ្លះ។ បើលោកអ្នកមិនយល់ស្រប, នោះលោកអ្នកអាចនិយាយជាមួយបុគ្គលិកគ្រប់គ្រងលក្ខណសម្បត្តិរបស់លោកអ្នក, ជាមួយចៅហ្វាយនៃបុគ្គលិកនេះ, ឬជាមួយអភិបាលនៃការិយាល័យសេវាសហគមន៍។ បើលោកអ្នកនៅតែមិនយល់ស្របទៀត, នោះលោកអ្នកស្នើសុំឲ្យគេបើកសវនាការរដ្ឋបាល (administrative hearing) មួយ ជូនបាន។

## ប្រសិនបើខ្ញុំមានលក្ខណសម្បត្តិ, តើខ្ញុំនឹងទទួលបានជំនួយអាហាររបស់ខ្ញុំនៅពេលណា?

នៅពេលលោកអ្នកដាក់ពាក្យសុំជំនួយជាលើកដំបូង, នោះជំនួយរបស់លោកអ្នកនឹងត្រូវបានចេញជូនភ្លាម បន្ទាប់ពីពេលដែលយើងបានទទួលពត៌មានដែលយើងត្រូវការសព្វគ្រប់ ដើម្បីសម្រេចមើល ថាតើលោកអ្នកពិតជាមានលក្ខណសម្បត្តិទទួលជំនួយឬទេ។ ជាធម្មតា នៅក្នុងរយៈពេល 30 ថ្ងៃ រាប់ចាប់ពីថ្ងៃដែលលោកអ្នកដាក់ពាក្យសុំ។ ប្រសិន



បើលោកអ្នកត្រូវការជំនួយជាបន្ទាន់ ហើយលោកអ្នកក៏មានលក្ខណសម្បត្តិទទួលជំនួយពន្លឿនផងដែរនោះ, នោះលោកអ្នកនឹងទទួលបានជំនួយរបស់លោកអ្នកនៅក្នុងរយៈពេល 7 ថ្ងៃ រាប់ចាប់ពីថ្ងៃ ដែលលោកដាក់ពាក្យសុំ។

នៅក្រោយថ្ងៃដែលការបែងចែកជំនួយជាលើកដំបូងត្រូវបានចេញជូនលោកអ្នក, នោះថ្ងៃនោះនឹងក្លាយជាថ្ងៃដែលលោកអ្នកត្រូវទទួលបានជំនួយអាហាររបស់លោកអ្នករៀងរាល់ខែ ដោយគ្មានការផ្លាស់ប្តូរ។ ជំនួយអាហាររបស់លោកអ្នកនឹងត្រូវគេផ្ញើជូនលោកអ្នកនៅចន្លោះថ្ងៃទី 1 និងថ្ងៃទី 10 រៀងរាល់ខែ។ ថ្ងៃជាក់លាក់ដែលលោកអ្នកនឹងបានទទួលជំនួយអាហាររបស់លោកអ្នកគឺអាស្រ័យលើខ្ទង់ចុងក្រោយនៃអត្តលេខក្នុង**អង្គភាពជំនួយអាហារ** (Food Assistance Unit, AU) របស់លោកអ្នក ដែលបានបោះពុម្ពភ្ជាប់ជូននៅលើលិខិតជូនដំណឹងស្តីពីការអនុម័តយល់ព្រមផ្តល់ជំនួយរបស់លោកអ្នក។ លោកអ្នកអាចទូរស័ព្ទទាក់ទងទៅលេខ 1-877-501-2233 ក៏បាន ដើម្បីស្វែងយល់ឲ្យដឹងច្បាស់ថា នៅរៀងរាល់ខែ តើជំនួយរបស់លោកអ្នកនឹងធ្លាក់មកដល់លោកអ្នកនៅថ្ងៃណា។

លោកអ្នកអាចប្រើប្រាស់ជំនួយរបស់លោកអ្នកបានរាល់ថ្ងៃ ដោយរាប់ទាំងថ្ងៃចុងសប្តាហ៍ និងថ្ងៃបុណ្យផង, ហើយអស់ទាំងជំនួយណា ដែលលោកអ្នកមិនទាន់បានប្រើប្រាស់, នោះលោកអ្នកអាចនឹងប្រើវាជាបន្តទៅទៀតបាននៅខែក្រោយៗទៀត។

## តើខ្ញុំនឹងទទួលជំនួយអាហារជាមូលដ្ឋានបានរយៈពេលយូរប៉ុណ្ណា?

**នៅពេលលោកអ្នកមានលក្ខណសម្បត្តិទទួលកម្មវិធីជំនួយអាហារជាមូលដ្ឋាន, នោះលោកអ្នកនឹងទទួលបានលិខិតមួយច្បាប់ពីយើងដែលនឹងបញ្ជាប់ប្រាប់លោកអ្នកអំពី ៖**

- ថាតើលោកអ្នកមានលក្ខណសម្បត្តិជំនួយឬទេ;
- លោកអ្នកមានលក្ខណសម្បត្តិទទួលជំនួយបានប៉ុន្មានខែ នៅក្នុងអាយុកាលនៃវិញ្ញាប័នកម្មរបស់លោកអ្នក; និង
- ចំនួននៃជំនួយអាហារដែលលោកអ្នកនឹងទទួលបាន។



នៅពាក់កណ្ដាលអាណត្តិនៃអាយុកាលវិញ្ញាប័នកម្មរបស់លោកអ្នក (ប្រាំមួយខែសម្រាប់ក្រុមគ្រួសារភាគច្រើន), លោកអ្នកនឹងទទួលបាន **លិខិតដាក់ពាក្យសុំការត្រួតពិនិត្យវិញ្ញាប័នកម្មពាក់កណ្ដាលអាណត្តិឡើងវិញ** (Mid-Certification Review) ដើម្បីបំពេញ។ យើងប្រើឯកសារ ដែលបានបំពេញក្នុងលិខិតនេះ ដើម្បីធ្វើបច្ចុប្បន្នភាពដល់ព័ត៌មាននានាស្ដីពីលោកអ្នក, មនុស្សទាំងប៉ុន្មានក្នុងផ្ទះរបស់លោកអ្នក, ប្រាក់ចំណូលនៃក្រុមគ្រួសាររបស់លោកអ្នក, និងការចាយវាយផ្សេងៗមួយចំនួនទៀត។ គោលដៅនៃការត្រួតពិនិត្យឡើងវិញនេះគឺដើម្បីធ្វើយ៉ាងណាឲ្យប្រាកដថា លោកអ្នកបានទទួលជំនួយទៅតាមចំនួនត្រឹមត្រូវ ស្របតាមលក្ខខណ្ឌ ដែលលោកអ្នកគប្បីទទួលបាន។ លោកអ្នកអាចធ្វើសម្ភាសន៍សម្រាប់ការត្រួតពិនិត្យឡើងវិញនេះតាមទូរស័ព្ទក៏បាន។

នៅក្នុងរយៈពេលប្រហែល 45 ថ្ងៃ មុនថ្ងៃផុតកំណត់នៃជំនួយអាហារជាមួយផ្ទានរបស់លោកអ្នក, នោះលោកអ្នកនឹងទទួលបានលិខិតជូនដំណឹងស្ដីពីការផុតកំណត់នេះ រួមជាមួយនឹង**ទម្រង់ដាក់ពាក្យសុំការត្រួតពិនិត្យលក្ខណសម្បត្តិឡើងវិញ** (Eligibility Review form) ដើម្បីបំពេញ បើសិនជាលោកអ្នកនៅចង់បន្តទទួលជំនួយអាហារ។

**ចូរបំពេញ ហើយផ្ញើទម្រង់ដាក់ពាក្យសុំការត្រួតពិនិត្យលក្ខណសម្បត្តិឡើងវិញ ទៅកាន់ ៖**

DSHS Customer Service Center
PO Box 11699
Tacoma, WA 98411-6699

លោកអ្នកនឹងទទួលបានសំបុត្រមួយច្បាប់ ដើម្បីបញ្ជាក់ប្រាប់អំពីការធ្វើសម្ភាសន៍តាមទូរស័ព្ទ ឬតាម**ការិយាល័យសេវាសហគមន៍របស់ក្រសួងសេវាសង្គមកិច្ចនិងសុខាភិបាល** (DSHS Community Services Office)។ លោកអ្នកត្រូវតែបំពេញការធ្វើសម្ភាសន៍នេះ ដើម្បីស្វែងយល់ ថាតើលោកអ្នកមានលក្ខណសម្បត្តិទទួលជំនួយអាហារឬទេ។



## តើក្រសួងមានច្បាប់ស្ដីពីការមិនរើសអើងឬទេ?

យោងតាមច្បាប់សហព័ន្ធ និងគោលនយោបាយរបស់ក្រសួងកសិកម្មនៃសហរដ្ឋ

អាមេរិក (U.S. Department of Agriculture, USDA), នោះស្ថាប័ននេះត្រូវបានហាមឃាត់ពីការរើសអើងចំពោះជាតិសាសន៍, ពណ៌សម្បុរ, ជាតិដើម, ភេទ, អាយុ, សាសនា, ជំនឿនយោបាយ, ឬពិការភាព។

**ដើម្បីដាក់បណ្តឹងអំពីការរើសអើង, ចូរសរសេរលិខិតទៅកាន់ ៖**
USDA, Director, Office of Civil Rights
1400 Independence Avenue, S.W.
Washington, D.C. 20250-9410

ឬទូរស័ព្ទទាក់ទងទៅលេខ (800) 795-3272 (សម្លេង) ឬលេខ (202) 720-6382 (បណ្តាញ TTY)។ ក្រសួង USDA គឺជាស្ថាប័នផ្តល់សេវាបម្រើ និងក៏ជានិយោជក ដែលផ្តល់ឱកាសស្មើភាពគ្នា ដល់ពលរដ្ឋគ្រប់រូប។

## តើប័ណ្ណ Washington EBT QUEST ជាអ្វី?

ប្រព័ន្ធផ្ទេរប្រាក់ជំនួយតាមប្រព័ន្ធអេឡិចត្រូនិច (Electronic Benefits Transfer, EBT) គឺជាប្រព័ន្ធមួយដ៏មានសុវត្ថិភាព, ងាយស្រួល, និងឆាប់រហ័សសម្រាប់លោកអ្នកទទួលប្រាក់ជំនួយអាហាររបស់លោកអ្នករាល់ខែ។

- លោកអ្នកត្រូវតែប្រើប័ណ្ណ ដើម្បីប្រើប្រាក់ជំនួយរបស់លោកអ្នក។
- ប័ណ្ណនេះអាចធ្វើដំណើរការស្រដៀងគ្នាទៅនឹងប័ណ្ណ ATM ដែរ, ក៏ប៉ុន្តែប្រាក់ជំនួយអាហារដែលផ្ទុកនៅក្នុងប័ណ្ណនេះ អាចប្រើបានត្រឹមតែទិញម្ហូបអាហារបរិភោគប៉ុណ្ណោះ។
- ប្រាក់ជំនួយរបស់លោកអ្នកនឹងត្រូវគេដាក់បញ្ចូលទៅក្នុងគណនីមួយ ដែលគេបានរៀបចំបង្កើតឡើងសម្រាប់លោកអ្នក។
- ប្រាក់ជំនួយរបស់លោកអ្នកអាចប្រើបានតែតាមរយៈការប្រើជាមួយលេខសម្គាល់ខ្លួនសម្ងាត់ (PIN) របស់លោកអ្នកប៉ុណ្ណោះ។



## តើលេខ EBT PIN ជាអ្វី?

រាល់ពេលលោកអ្នកប្រើប័ណ្ណរបស់លោកអ្នក, លោកអ្នកត្រូវតែបញ្ចូលលេខសម្ងាត់ 4 លេខ។ លេខទាំងនេះត្រូវបានហៅថា ៖

PIN (Personal Identification Number (លេខសម្គាល់ខ្លួន))

**** = PIN (លេខសម្ងាត់ 4 លេខ)

**ខាងក្រោមនេះគឺជាសេចក្តីណែនាំអំពីរបៀបជ្រើសរើស PIN ៖**

- បើលោកអ្នកទទួលប័ណ្ណរបស់លោកអ្នកនៅផ្ទាល់នឹងការិយាល័យ DSHS, នោះលោកអ្នកនឹងជ្រើសរើស PIN របស់លោកអ្នកនៅក្នុងពេលនោះតែម្តង។
- បើលោកអ្នកទទួលប័ណ្ណរបស់លោកអ្នកតាមសំបុត្រ – លោកអ្នកត្រូវតែទូរស័ព្ទទាក់ទងទៅការិយាល័យនាយកដ្ឋានសេវាបម្រើភ្ញៀវ (Sustomer Service) ដើម្បីជ្រើសរើស PIN ថ្មី ឬ PIN ជំនួស។

ចូរកុំចោល PIN នេះឲ្យសោះ! លោកអ្នកត្រូវការលេខទាំង 4 លេខនេះ ហើយនិងប័ណ្ណរបស់លោកអ្នក ដើម្បីប្រើជំនួយរបស់លោកអ្នក។

ចូរកុំសរសេរ PIN នៅលើប័ណ្ណរបស់លោកអ្នក ហើយចូរកុំឲ្យ PIN របស់លោកអ្នកទៅនរណាប្រើ ក្រៅពីមនុស្សក្នុងក្រុមគ្រួសាររបស់លោកអ្នក! ចូររក្សាទុក PIN របស់លោកអ្នកនៅកន្លែងណាមួយដែលសុវត្ថិភាព ហើយចូរកុំទុក PIN និងប័ណ្ណរបស់លោកអ្នកក្នុងកាបូបតែមួយជាមួយគ្នា។

បើប័ណ្ណរបស់លោកអ្នកបាត់ ឬខូច, នោះ PIN របស់លោកអ្នកនៅអាចប្រើបានជាធម្មតា។ ប័ណ្ណថ្មីរបស់លោកអ្នកនឹងប្រើ PIN ដដែលនេះ។ PIN នឹងមិនមានការផ្លាស់ប្តូរឡើយ លើកលែងតែលោកអ្នកស្នើសុំឲ្យគេផ្លាស់ប្តូរវា។

## តើអ្នកកាន់ប័ណ្ណជំនួសជាអ្វី?

លោកអ្នកអាចរើសរកមនុស្សណាម្នាក់ ឲ្យជួយប្រើជំនួយរបស់លោកអ្នក ជួសលោកអ្នក។ មនុស្សនេះត្រូវគេហៅថា អ្នកកាន់ប័ណ្ណជំនួស។

**អ្នកកាន់ប័ណ្ណជំនួស (Alternate Card Holder) ៖**

- ត្រូវបានជ្រើសរើសដោយលោកអ្នកផ្ទាល់។
- នឹងទទួលប័ណ្ណ Washington QUEST និង PIN ផ្ទាល់ខ្លួនរបស់ផងគេ ពីការិយាល័យ DSHS ប្រចាំមូលដ្ឋាន។
- នឹងអាចចាយវាយប្រាក់ជំនួយរបស់លោកអ្នកជួសលោកអ្នក។

បើលោកអ្នករើសរកមនុស្សណាម្នាក់ ឲ្យធ្វើជាអ្នកកាន់ប័ណ្ណជំនួសរបស់លោកអ្នក, នោះចូររើសរកមនុស្សណាដែលលោកអ្នកទុកចិត្ត។ សូមចាំថា បើជំនួយរបស់លោកអ្នកបាត់ ឬក៏ត្រូវគេលួច, នោះយើងនឹងគ្មានជំនួយទូទាត់អ្វីមួយជូនលោកអ្នកទេ។ ដើម្បីស្វែងយល់ពត៌មានពិស្តារបន្ថែម ឬស្នើសុំទម្រង់ផ្តល់សិទ្ធិអនុញ្ញាត (authorization form) សូមទូរស័ព្ទទាក់ទងទៅលេខ 1-877-501-2233 ។

## តើខ្ញុំគួរទូរស័ព្ទទាក់ទងទៅនាយកដ្ឋានសេវាបម្រើភ្ញៀវ EBT នៅពេលណា?

ខ្សែទូរស័ព្ទនៃនាយកដ្ឋានសេវាបម្រើភ្ញៀវ EBT
(EBT Customer Service)
1-888-328-9271

ខ្សែទូរស័ព្ទបន្តសេវានៃប្រព័ន្ធ TTY សម្រាប់មនុស្សគបឬថ្លង់ ៖
1-800-833-8388

ខ្សែទូរស័ព្ទបន្តសេវានៃប្រព័ន្ធ TTY សម្រាប់មនុស្សពិការភ្នែក
1-800-833-6385

### អាចទូរស័ព្ទទាក់ទង 24 ម៉ោងក្នុងមួយថ្ងៃ, 7 ថ្ងៃក្នុងមួយអាទិត្យ ដោយឥតគិតថ្លៃ នៅពេលណា ៖

- លោកអ្នកត្រូវការចង់ដឹងអំពីចំនួនប្រាក់អាហារ ឬប្រាក់សុទ្ធដែលនៅសល់ក្នុងគណនីរបស់លោកអ្នក។
- ប័ណ្ណរបស់លោកអ្នកបានបាត់, ត្រូវគេលួច, ឬខូច។
- លោកអ្នកចង់ស្តាប់របាយការណ៍ស្តីពីការចាយវាយចំនួន 10 ដងចុងក្រោយបង្អស់សម្រាប់ជំនួយប្រាក់សុទ្ធ ឬប្រាក់អាហារក្នុងគណនីរបស់លោកអ្នក។
- លោកអ្នកចង់ឲ្យគេផ្ញើប័ណ្ណថ្មី ឬលេខ PIN ថ្មី ទៅជូនលោកអ្នកតាមសបុត្រ។

### បុគ្គលិកតំណាងការិយាល័យនាយកដ្ឋានសេវាបម្រើភ្ញៀវក៏អាចជួយលោកអ្នកដែរ ដើម្បី ៖

- ស្វែងរកកន្លែងផិត។ ដែលលោកអ្នកអាចប្រើប័ណ្ណរបស់លោកអ្នក។
- រកឯកសារប្រវត្តិចាយវាយប្រាក់ជំនួយរបស់លោកអ្នកចំនួន 2 ខែ។
- រាយការណ៍អំពីបញ្ហានានា ដែលកើតមាននៅក្នុង ATM ។
- បើលោកអ្នកនិយាយភាសាអ្វីមួយផ្សេងពីភាសាអង់គ្លេស។

## តើខ្ញុំអាច និងមិនអាចធ្វើអ្វីបានខ្លះជាមួយប័ណ្ណ EBT និងជំនួយរបស់ខ្ញុំ?

ការប្រើប្រាស់ប័ណ្ណ Washington QUEST របស់លោកអ្នកមិនត្រឹមត្រូវគឺជាបទឧក្រិដ្ឋល្មើសនឹងច្បាប់រដ្ឋ និងច្បាប់សហព័ន្ធ!

### ការប្រើប្រាស់ត្រឹមត្រូវ

លោកអ្នក ឬសមាជិកនៃក្រុមគ្រួសាររបស់លោកអ្នកអាចប្រើជំនួយអាហាជាមូលដ្ឋាន (Basic Food) របស់លោកអ្នក ដើម្បីទិញគ្រឿងបរិភោគដូចជា ៖

- នំបុ័ង និងនំស្មៀវរីយ៉ាល់ (cereals)
- ផ្លែឈើ និងបន្លែ
- ឈីស, ទឹកដោះគោ, និងផលិតផលដែលធ្វើពីទឹកដោះគោផ្សេងៗ
- សាច់, ត្រី, បសុសត្វ, និងស៊ុត
- គ្រឿងបរិភោគដទៃៗជាច្រើនទៀត ដែលមិនត្រូវបានដាក់លក់ជាអាហារចម្អិនក្ដៅៗ
- គ្រាប់ធញ្ញជាតិ និងរុក្ខជាតិនានា ដែលបង្កើតផលផ្លែជាអាហារ

### ការប្រើប្រាស់ល្មើសច្បាប់

វាជាការល្មើសច្បាប់ ប្រសិនបើលោកអ្នក ៖

- ប្រើជំនួយអាហារដែលផ្ទុកក្នុងប័ណ្ណ EBT របស់លោកអ្នកសម្រាប់គោលបំណងណាមួយក្រៅពីការទិញម្ហូបអាហារសម្រាប់សមាជិកគ្រួសារទាំងប៉ុន្មាន ដែលមានលក្ខណសម្បត្តិសម្រាប់ជំនួយនេះ។
- យកជំនួយអាហាររបស់លោកអ្នក ទៅដូរយករបស់មានតម្លៃផ្សេងៗ (ការជួញដូរខុសច្បាប់)។ ឧទាហរណ៍នៃការជួញដូរខុសច្បាប់រួមមានដូចជា ការយកជំនួយអាហារ ទៅដូរយកប្រាក់សុទ្ធ, ថ្នាំជក់, គ្រឿងអាវុធ, ឬរបស់អ្វីមួយក្រៅពីការទិញម្ហូបអាហារនៅតាមហាងលក់ទំនិញ ដែលមានច្បាប់អនុញ្ញាតនានា។
- ឲ្យជំនួយរបស់លោកអ្នកទៅនរណាម្នាក់ ដែលមិនមែនជាមនុស្សក្នុងក្រុមគ្រួសារ ដែលមានលក្ខណសម្បត្តិទទួលជំនួយអាហារជាមូលដ្ឋាន។
- ប្រើជំនួយអាហារជាមូលដ្ឋាន ដើម្បីទិញរបស់របរដែលមិនមែនជាម្ហូបអាហារ ដូចជាបារី, ថ្នាំជក់, ស្រាបៀរ, ស្រាវាញ, ស្រាអាកុល, គ្រឿងឧបភោគសម្រាប់ប្រើប្រាស់ក្នុងគ្រួសារ, សាប៊ូ, ក្រដាស, ថ្នាំវិតាមីន, ម៉ាស៊ីន, ឬចំណីសត្វ។



## ទោសបញ្ញត្តិសម្រាប់ការប្រើប្រាស់ល្មើសច្បាប់

ប្រសិនបើលោកអ្នកប្រើប្រាស់ជំនួយអាហារជាមូលដ្ឋានរបស់លោកអ្នកមិនត្រឹមដោយចេតនា, នោះលោកអ្នកអាចនឹង ៖

- អស់គុណសម្បត្តិ ហើយបាត់បង់ជំនួយរបស់លោកអ្នក ចាប់ពីយ៉ាងតិចបំផុតមួយឆ្នាំ រហូតដល់អស់មួយជីវិត។ ការអស់គុណសម្បត្តិនេះនឹងបន្តនិរន្តរភាពរបស់វាទៅកំណត់ពេលបើទោះណាជាលោកអ្នកបានរើទៅរស់នៅក្នុងរដ្ឋណាមួយផ្សេងទៀតក៏ដោយក្តី។
- ស្ថិតជាកម្មវត្ថុចំពោះការផាកពិន័យផ្សេងៗ។
- ស្ថិតជាកម្មវត្ថុចំពោះចំណាត់ការផ្លូវច្បាប់, ដែលអាចរួមមានទាំងការជាប់ទោសអំពីបទឧក្រិដ្ឋផង។ ក្រសួង DSHS នឹងធ្វើសហការជាមួយអាជ្ញាធររដ្ឋ, អាជ្ញាធរមូលដ្ឋាន, និងអាជ្ញាធរសហព័ន្ធ ដើម្បីកាត់ទោសជនណា ដែលជួញដូរជំនួយអាហារជាមូលដ្ឋាន ឬជំនួយ SNAP ។

## ប្រើជំនួយរបស់លោកអ្នកឲ្យបានទាន់ពេល

ជំនួយអាហាររបស់លោកអ្នកត្រូវបានផ្តល់ជូន ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការបច្ចុប្បន្នទានារបស់ក្រុមគ្រួសារលោកអ្នក។

- ប្រសិនបើលោកអ្នកមិនប្រើប័ណ្ណរបស់លោកអ្នកអស់រយៈពេលច្រើនខែ, នោះយើងអាចនឹងទាក់ទងទៅលោកអ្នកដើម្បីសួរនាំឲ្យដឹងថា តើលោកអ្នកមានបញ្ហាក្នុងការប្រើប្រាស់ប័ណ្ណរបស់លោកអ្នកឬយ៉ាងណា ឬថាតើលោកអ្នកនៅតែត្រូវការជំនួយអាហារនេះជាបន្តទៅទៀតឬទេ។
- ប្រសិនបើលោកអ្នកមិនប្រើជំនួយរបស់លោកអ្នក យ៉ាងហោចក៏បានក្នុងចំនួនណាមួយនៅក្នុងរយៈពេល 365 ថ្ងៃទេនោះ, នោះជំនួយរបស់លោកអ្នកនឹងត្រូវគេលុបចោលហើយអាចនឹងគ្មានសំណងជួសជួលណាមួយត្រូវបានផ្តល់ជូនលោកអ្នកសោះឡើយ។

# សំណួរដែលគេសួរញឹកញាប់អំពីប័ណ្ណ EBT និងចម្លើយ

Q: តើលោកអ្នកអាចប្រើប័ណ្ណ EBT របស់លោកអ្នកនៅក្រៅរដ្ឋបានឬទេ?

A: ប័ណ្ណ Washington QUEST ត្រូវបានទទួលស្គាល់ទូទាំងប្រទេស នៅតាមហាងទាំងឡាយណា ដែលចូលរួមក្នុងកម្មវិធី EBT ។ ចូររកមើលសញ្ញា QUEST ឬសាកសួរបុគ្គលិកហាងជាមុន មុននឹងលោកអ្នកប្រើប័ណ្ណ QUEST របស់លោកអ្នកនៅហាងណាមួយ។ ហាងលក់ម្ហូបអាហារខ្លះអាចជាហាងចូលក្នុងកម្មវិធី ហើយខ្លះទៀតអាចមិនមែនជាហាងចូលរួមក្នុងកម្មវិធីនេះទេ។ ការប្រើម៉ាស៊ីន ATM ដើម្បីដូរប្រាក់ជំនួយគឺវាអាស្រ័យលើថាតើម៉ាស៊ីន ATM មួយនោះត្រូវបានគេបើកប្រតិបត្តិការជាផ្នែកនៃបណ្ដាញ QUEST ឬទេ។

Q: តើលោកអ្នកអាចយកទំនិញ ដែលទិញដោយប័ណ្ណរបស់លោកអ្នក ទៅដូរយកប្រាក់វិញបានឬទេ?

A: បាន! ឧទាហរណ៍ថា ទឹកដោះគោដែលលោកអ្នកទើបតែនឹងទិញនោះវាខូច, លោកអ្នកអាចយកទឹកដោះគោរួមទាំងបង្កាន់ដៃទិញ ទៅដូរយកប្រាក់វិញបាន; គេនឹងបញ្ចូលប្រាក់ទៅក្នុងប័ណ្ណ ឬប្ដូរជាទម្រង់ណាមួយ ជូនលោកអ្នកវិញ។ ក៏ប៉ុន្តែ លោកអ្នកមិនអាចដូរយកប្រាក់សុទ្ធបានទេ ប្រសិនបើទំនិញទាំងនោះបានទិញដោយប័ណ្ណជំនួយរបស់លោកអ្នក។

Q: បើប្រាក់ជំនួយអាហារពីខែមុននៅសល់ក្នុងប័ណ្ណ EBT របស់ខ្ញុំ, តើខ្ញុំអាចដូរយកប្រាក់សុទ្ធបានទេ?

A: មិនបានទេ។ គ្រប់ទាំងប្រាក់ជំនួយអាហារដែលនៅសល់ពីខែមុន អាចប្រើប្រាស់បានជាបន្តទៅខែក្រោយៗទៀតតាមរយៈការប្រើប្រាស់ប័ណ្ណដូចសព្វៗដង។

Q: បើខ្ញុំផ្លាស់ទៅរស់នៅក្នុងរដ្ឋផ្សេង, តើខ្ញុំអាចនៅតែបន្តទទួលជំនួយអាហារជាមូលដ្ឋានបានឬទេ?

A: ជំនួយអាហារជាមូលដ្ឋាន (Basic Food) គឺសម្រាប់តែពលរដ្ឋ ដែលរស់នៅក្នុងវ៉ាស៊ីនតោនប៉ុណ្ណោះ។ លោកអ្នកត្រូវតែទូរស័ព្ទទៅមជ្ឈមណ្ឌលសេវាបម្រើភ្ញៀវតាមលេខ 1-877-501-2233 ដើម្បីបិទសំណុំរឿងរបស់លោកអ្នក ប្រយោជន៍លោកអ្នកអាចដាក់ពាក្យសុំ**កម្មវិធីជំនួយអាហារូបត្ថម្ភបំពេញបន្ថែម** (Supplemental Nutrition Assistance Program, SNAP) នៅក្នុងរដ្ឋ ដែលលោកអ្នកនឹងទៅរស់នៅនោះ។ លោកអ្នកនៅតែអាចប្រើប្រាស់ជំនួយដែលបានចេញជូនលើប័ណ្ណ EBT របស់លោកដដែល ដរាបណាលោកអ្នករស់នៅតែរស់នៅក្នុងរដ្ឋវ៉ាស៊ីនតោននៅឡើយ។

Take a Fresh Look

Basic Food

DSHS 22-297(CA) (Rev. 6/11)